ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៥១ សសរ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតក្រុមការងារសំរាប់ពិភាក្សាលើគំរោងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**ប្រការ ១** : បង្កើតក្រុមការងារមួយសំរាប់ពិភាក្សាលើគំរោងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ (VOTEC) ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១_ឯកឧត្តម | សយ សុខា | អគ្គលេខាធិការ OBSES | ប្រធាន |
| ២_ឯកឧត្តម | សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៣_ឯកឧត្តម | គ្រាញ់ ឌ.តូនី | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៤_ឯកឧត្តម | ពេជ្រ សោភ័ន | អគ្គនាយកឧត្តមសិក្សានិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៥_លោក | ជា ម៉ាន់ដេត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី | |
| ៦_លោក | វិម ទិសិដ្ឋ | ប្រធាននាយកដ្ឋានអប់រំ វប្បធម៌ សង្គមកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី | |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៧_លោក | ឈៅ យុទ្ធថា | តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៨_លោក | ឃួន រ៉ានីន | ជំនួយការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | សមាជិក |
| ៩_លោក | ម៉ែន សុចិត្រ | ប្រធាននាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | សមាជិក |
| ១០_លោក | ហ៊ូ ទុន្ណី | ប្រធាននាយកដ្ឋានការងារនៃក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |
| ១១_លោក | សួស យ៉ារ៉ា | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២_លោក | លន់ សុជាតិ | អនុប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |

**ប្រការ ២** : ក្រុមការងារនេះ មានភារកិច្ចដូចតទៅ ៖

_ពិនិត្យពិភាក្សាលើគំរោងសិក្សាលំអិត ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

_ទទួលពិនិត្យ និង ឆ្លើយសំណួរនានារបស់ភាគីកូរ៉េដែលទាក់ទងនឹងគំរោងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ

_រៀបចំបែបបទសំរាប់ដំណើរការគំរោង

_ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣** : ប្រធានក្រុមការងារមានសិទ្ធិជ្រើសរើសសមាជិកមួយរូបអោយទទួលចាត់ចែងការងារជំនួសក្នុងពេលអវត្តមាន ។

**ប្រការ ៤** : សមាជិកទាំងអស់នៃក្រុមការងារសំរាប់ពិភាក្សាលើគំរោងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបំពេញការងារតាមការបែងចែកភារកិច្ច ពីប្រធានក្រុមការងារ ។

**ប្រការ ៥** : សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ឯកឧត្តម អស់លោក ដែលមានរាយនាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ_កាលប្បវត្តិ

www.pheakdeylaw.com